គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី

Active People's Microfinance Institution Plc.

របាយការណ៍ប្រចាំឆ្នាំ 2022

ANNUAL REPORT 2022

គ្រឹះស្ថានឯកជន / Private Company

មាតិកា

១. សារពីអគ្គនាយក ១
ក. ស្ថានភាពទូទៅនៃសេដ្ឋកិច្ចពិភពលោក ១
ខ. សេដ្ឋកិច្ចកម្ពុជា ១
គ. ប្រព័ន្ធធនាគារនៅកម្ពុជា ២
ឃ. លទ្ធផលសម្រេចក្នុងឆ្នាំ២០២២ ..... ២
២. ប្រវត្តិសង្ខេប ៤
ក. ទស្សនៈវិស័យ ៥
ខ. បេសកកម្ម ៥
គ. ពាក្យស្លោករបស់គ្រឹះស្ថាន ៥
ឃ. គោលការណ៍ណែនាំ ៦
ង. ក្រមអនុវត្តន៍របស់ អាក់ទីវភីតល ភីអិលស៊ី ៦
៣. ព័ត៌មានប្រតិបត្តិការ ៦
ក. ផលប័ត្រឥណទានសរុប(ដុល្លារ) ៧
ខ. ចំនួនអតិថិជន ៧
គ. ចំនួនសាខា ៧
ឃ. សមតុល្យឥណទាន តាមផលិតផល ៧
៤. រចនាសម្ព័ន្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីតល ប្រចាំឆ្នាំ២០២២ ..... ១០
៥. ភាគទុនិក ១២
៦. ក្រុមប្រឹក្សាភិបាល ១២
៧. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ១៤
៨. គណៈគ្រប់គ្រង ១៥
៩. សកម្មភាពផ្សេងៗរបស់គ្រឹះស្ថាន ១៩
ក. អត្តពលកម្មប៉ារ៉ាឡាំពិក ១៩
ខ. កាកបាទក្រហមកម្ពុជា ២០
គ. កម្មពិធីលៀងសាយភោជន ២២
ឃ. បរិច្ចាគឈាម សង្គ្រោះជីវិត ពិតជួយសង្គមជាតិ ២៣
ង. ម៉ារ៉ាតុងលើកទី១០ ..... ២៤
ច. កម្មវិធីចាប់រង្វាន់ និងប្រគល់រង្វាន់ជូនដល់អតិថិជនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
អាក់ទីវភីតល ២០២២ ..... ២៥
ឆ. ចាប់រង្វាន់កាតសាំងជូនដល់អតិថិជន ២៦
ជ. ពិធីបើកដំណើរការកិច្ចសហប្រតិបត្តិការ សាលាបឋមសិក្សាព្រះនរោត្តមនិង
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីតល ភីអិលស៊ី ២៧
ឈ. គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ២៨
១០. ទីស្នាក់ការរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីល ភីអិលស៊ី ២៩

១. សារពីអគ្គនាយក

ក. ស្ថានភាពទូទៅនៃសេដ្ឋកិច្ចពិភពលោក

សកម្មភាពសេដ្ឋកិច្ចពិភពលោកនៅក្នុងឆ្នាំ២០២២មានការធ្លាក់ចុះខ្លាំងជាងការរំពឹងទុកបើធៀប នឹងឆ្នាំ២០២១។ ដោយសារឥទ្ធិពលសង្គ្រាមរវាងប្រទេសរុស្សី និងអ៊ុយក្រែន ការកើនឡើងខ្ពស់នៃអតិផរណា និងការរឹតត្បិតស្ថានភាពហិរញ្ញវត្ថុអន្តរជាតិទើបធ្វើឲ្យកំណើនសេដ្ឋកិច្ចសកលទាំងមូលមានភាពយឺតយ៉ាវខុសពីការគិតទុកបែបនេះ។ យោងតាមការព្យាករណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិកំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានប៉ាន់ស្មានថាថយល្បឿនមកនៅ ៣,៧% ក្នុងនោះសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍កើន ២,៤% និងប្រទេសកំពុងអភិវឌ្ឍន៍កើន ៣,៧% ខណៈដែលសេដ្ឋកិច្ចតំបន់អាស៊ានអាចរក្សាបានកំណើន ៥,២% ។

ខ. សេដ្ឋកិច្ចកម្ពុជា

យោងតាមរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់ធនាគារជាតិនៃកម្ពុជាអតិផរណាបានកើនឡើងដល់ ៥,៣% ខ្ពស់ជាងឆ្នាំ២០២១ (២,៩%) ដែលជាចម្បងបណ្តាលមកពីកំណើនថ្លៃប្រេងឥន្ធនៈ និងម្ហូបអាហារក្រោមឥទ្ធិពលសង្គ្រាមរវាងប្រទេសរុស្សីនិងអ៊ុយក្រែន និងភាពរអាក់រអួលខ្សែច្រវាក់ផ្គត់ផ្គង់សកលស្របពេលដែលតម្រូវការក្នុងស្រុកមានកំណើនជាលំដាប់ ។

ចំពោះកំណើនសេដ្ឋកិច្ចបានបន្តដើរឡើងក្នុងអត្រា ៥,១%ដែលគាំទ្រជាចម្បងដោយការបើកទូលាយសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកឡើងវិញ និងកំណើនតម្រូវការខាងក្រៅ។ វិស័យកម្មន្តសាលសម្រេចកំណើនដែលក្នុងនោះផលិតផលកាត់ដេរសម្រាប់នាំចេញកើន ៦៤,៣%ផលិតផលមិនមែនកាត់ដេរសម្រាប់នាំចេញកើន ១,១ដង និងផលិតផលកម្មន្តសាលសម្រាប់បម្រើទីផ្សារក្នុងស្រុកកើន ៨៨,៥%។ ជាមួយគ្នានេះវិស័យទេសចរណ៍មានកំណើនល្អ ដោយភ្ញៀវអន្តរជាតិបានកើនឡើងខ្ពស់ជាងការរំពឹងទុករហូតដល់ ២,២ លាន

នាក់ បើទោះជានៅមានកម្រិតត្រឹម ១/៣ នៃគ្រាមុនវិបត្តិកូវីដ១៩ ក៏ដោយ ខណៈដែលទេសចរណ៍ក្នុងស្រុកបានវិលមកប្រក្រតីភាពទាំងស្រុង។ វិស័យសំណង់ និងអចលនទ្រព្យមានកំណើនទាបត្រឹម ០,៨% និង ០,៥% រៀងគ្នា ដែលគាំទ្រដោយកំណើនតម្រូវការក្នុងស្រុកស្របពេលដែលវិស័យកសិកម្មបន្តកើនឡើងក្នុងល្បឿនយឺតត្រឹម ០,៧% ដែលបណ្តាលមកពីទឹកភ្លៀងធ្លាក់លឿននិងមានបរិមាណច្រើន និងការកើនឡើងថ្លៃដើមផលិតដោយសារការឡើងថ្លៃប្រេងឥន្ធនៈ និងជីកសិកម្ម។ជញ្ជីងទូតទាត់ត្រូវបានប៉ាន់ស្មានថាមានភាពប្រសើរឡើងដោយមានអតិរេក ២៩៨,៨ លានដុល្លារអាមេរិក ដោយសារលំហូរចូលនៃគណនីហិរញ្ញវត្ថុ និងការថយចុះខ្ទីនភាពគណនីចរន្ត និងដើមទុន។ ទុនបម្រុងអន្តរជាតិមានកម្រិតខ្ពស់គ្រប់គ្រាន់ ទោះបីជាបានថយចុះបន្តិចក្តី ដោយមានចំនួនប្រមាណ ១៧,៨ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ៧ខែ នៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ ខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (៣ខែ)។

គ. ប្រព័ន្ធធនាគារនៅកម្ពុជា

យោងតាមរបាយការណ៍ប្រចាំឆ្នាំ២០២២ របស់ធនាគារជាតិនៃកម្ពុជា ស្ថានភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជាបន្តមានសុខភាពល្អ ព្រមទាំងបានរួមចំណែកគាំទ្រការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច ។ ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារបានកើនឡើង ១៤,៥% ឥណទានទៅកាន់វិស័យចម្បងៗមានកំណើន ២០,២% និងប្រាក់បញ្ញើអតិថិជនកើន ១១,៣% ។ បរិយាបន្នហិរញ្ញវត្ថុបានកើនឡើងជាលំដាប់ដែលឆ្លុះបញ្ចាំងដោយកំណើនចំនួនគណនីប្រាក់បញ្ញើអតិថិជនពី ១២,៧ លាន ដល់ ១៤,៣ លានគណនី និងគណនីឥណទានអតិថិជនពី ៣,៤ លាន ដល់ ៣,៧ លានគណនី ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានផ្តល់អនុគ្រោះដល់អ្នកខ្វីប្រាក់ តាមរយៈការរៀបចំឥណទានឡើងវិញចំនួន ១៨៣.១១៧ គណនី (ថយ -៤៩%) ដែលមានទំហំឥណទាន ៣,៣ ប៊ីលានដុល្លារអាមេរិក (ថយ-៣៨%) ដើម្បីរួមចំណែកជួយសម្រាលបន្ទុកប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩និងគ្រោះទឹកជំនន់។ឥណទានបន្តមានគុណភាពល្អដោយអនុបាតឥណទានមិនដំណើរការសម្រាប់វិស័យធនាគារមានកម្រិត ៣,២% និងវិស័យមីក្រូហិរញ្ញវត្ថុ ២,៦% ។ ទន្ទឹមនេះ ស្ថានភាពដើមទុននិងសន្ទនីយភាពមានភាពរឹងមាំដោយ អនុបាតសាធនភាពមានកម្រិតខ្ពស់ដល់ ២២,៥% សម្រាប់វិស័យធនាគារ និង ២១,២% សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ធៀបនឹងកម្រិតអប្បបរមាកំណត់ដោយបទប្បញ្ញត្តិ ១៥%ហើយអនុបាតក្របខ័ណ្ឌសន្ទនីយភាពមានអត្រា ១៤៣%សម្រាប់គ្រឹះស្ថានធនាគារ ពាណិជ្ជ និង១៧២,៨%សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ខ្ពស់ជាងកម្រិតអប្បបរមាកំណត់ដោយបទប្បញ្ញត្តិ ១០០%។

ឃ. លទ្ធផលសម្រេចក្នុងឆ្នាំ២០២២

នៅក្នុងឆ្នាំ២០២២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាក់ទីវភីតល សម្រេចបានក្លាយជាគ្រឹះស្ថានដែលឈានមុខគេក្នុងសកម្មភាពហិរញ្ញវត្ថុនៅក្នុងប្រទេស។អស់រយៈពេល១១ឆ្នាំដែលអាក់ទីវភីតលបានឈរជើងប្រកបដោយស្ថេរភាពក្នុងទិសដៅជួយជំរុញបង្កើនជីវភាពប្រជាពលរដ្ឋកម្ពុជានិងគាំទ្រដល់រដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។នៅចុងឆ្នាំ ២០២២ គ្រឹះស្ថានសម្រេចបាននូវទ្រព្យសកម្មសរុបចំនួន ២៨១,៦៩៥,៣០៩ ដុល្លារអាមេរិក ក្នុងនោះមានផលប័ត្រឥណទានសរុប ២៤៨,៦២០,៤៩៧ ដុល្លារអាមេរិក និងផ្តល់ជូនអតិថិជនសរុប

ចំនួន ១៧៨,១៦២ គណនី ជាមួយសកម្មភាពប្រតិបត្តិការចំនួន ២៩ សាខា និងបុគ្គលិកចំនួន ៥៧០ នាក់ ។ ការងើបឡើងវិញនៃដំណើរការសេដ្ឋកិច្ចបន្ទាប់ពីវិបត្តិកូវីដ១៩ រយៈពេល២ឆ្នាំកន្លងទៅ នៅក្នុងឆ្នាំ២០២២ នេះ គ្រឹះស្ថានទទួលបានប្រាក់ចំនេញសុទ្ធចំនួន ១០,៩៦៦,២៥០ ដុល្លារអាមេរិក ដែលជាចំនួនមួយដែលមិនធ្លាប់ទទួលបានពីមុន ។ គ្រឹះស្ថាននៅតែបន្តអនុវត្តយុទ្ធសាស្ត្របង្កើនទ្រព្យសកម្មរបស់ខ្លួនតាមរយៈការផ្តល់ឥណទាន ជូនអតិថិជនឲ្យកាន់តែទូលំទូលាយ និងមានប្រសិទ្ធិភាព។ បន្ថែមលើការផ្តល់ឥណទាន គ្រឹះស្ថានយើងខ្ញុំក៏បានចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលតាមរយៈសមាគមមីក្រូហិរញ្ញវត្ថុនៃកម្ពុជាក្នុងយុទ្ធនាការបរិច្ចាគឈាមនិងជំនួយមនុស្សធម៌សម្រាប់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយសារគ្រោះទឹកជំនន់នៅខេត្តកំពង់ធំផងដែរ ។ ជាពិសេសទៅទៀតនោះចាប់ពីឆ្នាំ២០២០មក គ្រឹះស្ថានតែងតែបន្ត សកម្មភាពរបស់ខ្លួនដោយផ្ទាល់ក្នុងការបរិច្ចាគថវិកាមួយចំនួនជូនកាកបាទក្រហមកម្ពុជាជារៀងរាល់ឆ្នាំហើយ នៅក្នុងឆ្នាំ២០២២ នេះផងដែរ គ្រឹះស្ថានបានបរិច្ចាគថវិកាជូនកាកបាទក្រហមកម្ពុជាចំនួន ២០,០០០,០០០ រៀល ។ លើសពីនេះទៅទៀតគ្រឹះស្ថានបានបន្ថែមការបរិច្ចាគ ៣០០០ ដុល្លារអាមេរិក ដើម្បីជួយសម្រាលការលំបាកចំពោះប្រជាពលរដ្ឋដែលបានទទួលរងផលប៉ះពាល់ដោយសារគ្រោះទឹកជំនន់នាខែតុលាឆ្នាំ២០២២ កន្លងទៅនេះ ។

ការរីកចម្រើនរបស់អាក់ទីវភីតលរហូតមកដល់ពេលនេះនិងតទៅមុខទៀតគឺដោយសារការចូលរួមសហការល្អរបស់បុគ្គលិកគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។ ជំនួសមុខឲ្យក្រុមប្រឹក្សាភិបាលខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈគ្រប់គ្រងនិងបុគ្គលិករបស់អាក់ទីវភីតលទាំងអស់ដែលបានខិតខំប្រឹងប្រែងអស់កម្លាំងកាយចិត្តបំពេញតួនាទីភារកិច្ចរៀងៗខ្លួនបានយ៉ាងល្អរហូតទទួលបានភាពជោគជ័យគួរឲ្យកត់សម្គាល់ហើយ សូមការព្យាយាមប្រឹងប្រែងនេះនៅតែបន្តដើម្បីផ្តល់សេវាកម្មដ៏ល្អប្រសើរជូនអតិថិជនគ្រប់ៗគ្នា។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណផងដែរចំពោះ ភាគទុនិក ក្រុមប្រឹក្សាភិបាល អតិថិជន រាជរដ្ឋាភិបាលជាពិសេសធនាគារជាតិនៃកម្ពុជា ដែលបានគាំទ្រ និងផ្តល់ដំបូន្មានល្អៗជារៀងរហូតមក។

សមាជិកក្រុមប្រឹក្សាភិបាល/អគ្គនាយក

TATSUHIRO KURIHARA

២. ប្រវត្តិសង្ខេប

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ៉ាភីតល ភីអិលស៊ី ហៅកាត់ថា(អេភី) បានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលមានលេខអាជ្ញាប័ណ្ណ00009४२९ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១ និងទទួលអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ពីធនាគារជាតិនៃកម្ពុជា (NBC) ដើម្បីធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ រៀងមក ហើយបច្ចុប្បន្នគ្រឹះស្ថានមានចំនួន ២९ សាខា ។

២០១១

- ទទួលអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ពីធនាគារជាតិនៃកម្ពុជា
- ចុះបញ្ជីនៅ ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនាមជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

២០១២

- បង្កើនដើមទុនពី ៣00.000ដុល្លារអាមេរិក ដល់ ៧९១.८00ដុល្លារអាមេរិក
- មានទីតាំងនៅផ្ទះលេខ ១८९សេ ផ្លូវលេខ១८៣ សង្កាត់ចឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

២០១៣

- បង្កើនដើមទុនពី ៧९១.८00ដុល្លារអាមេរិក ដល់ ५.00១.८00ដុល្លារអាមេរិក ផ្លាស់ប្តូរទីតាំងថ្មីដែលមានអាសយដ្ឋាននៅអាគារលេខ៣५-៣៧ ផ្លូវលេខ២១८ សង្កាត់ចឹងរ៉ាង ខណ្ឌ៧មករា រាជធានីភ្នំពេញ
- បង្កើតសាខាខេត្តសៀមរាប និងសាខាខណ្ឌចឹងកេងកង៣

២០១४

- បង្កើតសាខាខណ្ឌសែនសុខ

២០១५

- បង្កើនដើមទុនពី५.00១.८00 ដុល្លារអាមេរិក ដល់ ८.५01.८00 ដុល្លារអាមេរិក

២០១६

- បង្កើនដើមទុនពី ८.५01.८00 ដុល្លារអាមេរិក ដល់ ១0.00១.८00 ដុល្លារអាមេរិក
- បង្កើតសាខាខេត្តបាត់ដំបង និងសាខាខេត្តកំពង់ចាម

២០១៧

- ផ្លាស់ប្តូរទីតាំងគឺស្នាក់ការកណ្តាលថ្មី ដែលមានអាសយដ្ឋាននៅ អាគារលេខ៨៨ ផ្លូវលេខ២១៤ កែងនឹង ផ្លូវ១១៣ ភូមិ៤ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ
- បង្កើតសាខា ខេត្តកណ្តាល សាខាខេត្តតាកែវ និងសាខាខណ្ឌទួលគោក

២០១៨

- បង្កើត សាខាខណ្ឌមានជ័យ ខណ្ឌច្បារអំពៅ ខណ្ឌជ្រោយចង្វា ខេត្ត បន្ទាយមានជ័យ និងខេត្តកំពង់ស្ពឺ

២០១៩

- បង្កើត សាខាខេត្តត្បូងឃ្មុំ និងសាខាខណ្ឌព្រែកព្នៅ

២០២០

- បង្កើតសាខា ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តក្រចេះ និងខេត្តរតនៈគិរី
- បង្កើនដើមទុនពី ១០.០០១.៨០០ ដុល្លារអាមេរិក ដល់ ២០.០០០.០០០ ដុល្លារអាមេរិក២០២១

២០២១

- បង្កើតសាខា ស្រុកបារាយណ៍ ឃុំបល្ល័ង្ក (ខេត្តកំពង់ធំ), សាខាខេត្តព្រះវិហារ, សាខាខេត្តឧត្តរមានជ័យ, សាខាខណ្ឌដង្កោ, សាខាខណ្ឌពោធិ៍សែនជ័យ, សាខាខេត្តកំពត, សាខាក្រុងប៉ោយប៉ែត, សាខាខេត្តស្វាយរៀង, សាខាស្រុកពាមរក៍ ឃុំព្រែកខ្សាយ ខ(ខេត្តព្រៃវែង)

ក. ទស្សនៈវិស័យ

- យើងមានបំណងក្លាយទៅជាគ្រឹះស្ថានហិរញ្ញវត្ថុមួយឈានមុខគេ តាមរយៈការផ្តល់សេវាកម្មល្អប្រសើរ និងរីកចម្រើនប្រកបដោយស្ថេរភាព ។

ខ. បេសកកម្ម

- យើងធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា តាមរយៈការចូលរួម និងផ្តល់នូវឥណទានដោយប្រកាន់ខ្ជាប់ភាពជាដៃគូនៃអាជីវកម្មហិរញ្ញវត្ថុ ។

គ. ពាក្យស្លោករបស់គ្រឹះស្ថាន

- យើងស្តាប់លោកអ្នក គិតជាមួយលោកអ្នកដើម្បីបង្កើត ដំណោះស្រាយដ៏ល្អបំផុតសម្រាប់ភាពជោគជ័យរបស់លោកអ្នក ។

២. គោលការណ៍ណែនាំ

- អាក់ទីវ៉ាភីតល ភីអិលស៊ី នឹងផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាពលរដ្ឋកម្ពុជាទូទៅដោយមិនប្រកាន់វណ្ណៈ ។
- អាក់ទីវ៉ាភីតល ភីអិលស៊ី នឹងផ្តល់សេវាហិរញ្ញវត្ថុដែលមានលក្ខណៈបត់បែន និងងាយស្រួលជាងគេ។
- អាក់ទីវ៉ាភីតល ភីអិលស៊ី ប្តេជ្ញាគោរព និងឲ្យតម្លៃអតិថិជនរបស់ខ្លួនជាអាទិភាព។
- អាក់ទីវ៉ាភីតល ភីអិលស៊ី ប្តេជ្ញាប្រកាន់ខ្ជាប់នូវអត្តចរិក និងស្តង់ដារការងារដើម្បី ធានាបាននូវភាពជឿជាក់។
- អាក់ទីវ៉ាភីតល ភីអិលស៊ី ប្តេជ្ញាផ្តល់សេវាកម្ម និងទំនាក់ទំនងល្អបំផុតដល់ប្រជាពលរដ្ឋគ្រប់រូប។
- អាក់ទីវ៉ាភីតល ភីអិលស៊ី ជាគ្រឹះស្ថានរៀនសូត្រដែលមានការផ្លាស់ប្តូរ និងការចែករំលែកនូវព័ត៌មានសមស្របដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍បុគ្គលិក ការបណ្តុះបណ្តាល ព្រមទាំងរួមចំណែកក្នុងការកែលម្អគោលការណ៍ និងប្រព័ន្ធ។

១. ក្រមអនុវត្តន៍របស់ អាក់ទីវ៉ាភីតល ភីអិលស៊ី

- ការជៀសវាងបំណុលលើសលប់ ៖ យើងនឹងផ្តល់ឥណទានតាមលទ្ធភាពសងរបស់អតិថិជន និងរកវិធីដើម្បីបញ្ជៀសបំណុលលើសលប់តាមដែលអាចធ្វើបាន។
- ក្រមសីលធម៌របស់បុគ្គលិក ៖ យើងមានការអប់រំបន្ថែម និងប្រកាន់ខ្ជាប់នូវតរិយាបថប្រកបដោយក្រមសីលធម៌ខ្ពស់ គោរពចំពោះអតិថិជនគ្រប់មជ្ឈដ្ឋានពីបុគ្គលិកគ្រប់លំដាប់ថ្នាក់។
- សេរីភាពក្នុងការជ្រើសរើស ៖ អតិថិជនមានសិទ្ធិជ្រើសរើសផលិតផល និងសេវាកម្មរបស់យើងដែលសមស្របនឹងមុខរបរឬតម្រូវការ។
- យន្តការឆ្លើយតបចំពោះមតិយោបល់ ៖ យើងនឹងទទួលយកនូវមតិយោបល់ និងឆ្លើយតបអោយបានសមរម្យបំផុត ។

៣. ព័ត៌មានប្រតិបត្តិការ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២

ឆ្នាំ	២០១៨	២០១៩	២០២០	២០២១	២០២២
ផលប័ត្រឥណទានសរុប(ដុល្លារ)	៤០,៣៨៨,១៧១	៦៥,៨៤១,៤៤២	១០២,៧៣៩,១៤៨.០៨	១៤៨,៦១៣,៦១២.០៣	២៤៨,៦២០,៤៩៧
ចំនួនសាខា	១៤	១៦	២០	២៩	២៩
ចំនួនអតិថិជន	៥២,៤៣១	៧៩,៤៦៥	១១៣,១០៤	១៣៩,៨៧៩	១៧៨,១៦២

ក. ផលចំត្រតណានានសរុប(ដុល្លារ)



ខ. ចំនួនសាខា



គ. ចំនួនអតិថិជន



ឃ. សមតុល្យឥណទាន តាមផលិតផល

ប្រភេទផលិតផល	២០២១	២០២២
បង់រំលស់គ្រឿងចក្រកសិកម្ម	៥៤៩,៤២០	៥០១,៥៣៨
បង់រំលស់រថយន្ត	២១,៩១១,៩៣៣	៦០,៧៧៣,០២០
បង់រំលស់គ្រឿងអេឡិចត្រូនិច	៨,៦៨១,៧៧៩	៩,១៩៦,២៨៤
បង់រំលស់ដី	៤៤៤,៦៨២	២៥៤,៧៦៣
បង់រំលស់ម៉ូតូ	៩០,៥១៣,០៨០	១៤៨,៨៩៣,០៣៥
ឥណទានរហ័ស	២៥,២៦៧,៤៤៤	១,០៨៦,០១១
ឥណទានប្រើប្រាស់ទូទៅ	១,២៤៥,២៧៤	២៧,៩១៥,៨៤៦
សរុប(ដុល្លារ)	១៤៨,៦១៣,៦១២	២៤៨,៦២០,៤៩៧


សមតុល្យឥណទាន តាមផលិតផល
សរុប(ដុល្លារ)
ឥណទានប្រើប្រាស់ទូទៅ
ឥណទានរហ័ស
បង់រំលស់ម៉ូតូ
បង់រំលស់ដី
បង់រំលស់គ្រឿងអេឡិចត្រូនិច
បង់រំលស់រថយន្ត
បង់រំលស់គ្រឿងចក្រកសិកម្ម
0
៥0,000,000
១00,000,000
១៥0,000,000
២00,000,000
២៥0,000,000
៣00,000,000
សមតុល្យឥណទាន តាមផលិតផល
សមតុល្យឥណទាន តាមផលិតផល

៤. រចនាសម្ព័ន្ធរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ប្រចាំឆ្នាំ២០២២




គណៈកម្មាធិការ
គ្រប់គ្រងហានិភ័យ
គណៈកម្មាធិការ
តែងតាំង
និងអត្តប្រយោជន៍
គណៈកម្មការ
ឥណទាន
គណៈកម្មការ
ធនធានមនុស្ស
នាយិកានាយក
ដ្ឋានហិរញ្ញវត្ថុ
នាយក
ដ្ឋានសវនកម្មផ្ទៃក្នុង
នាយិកានាយក
ដ្ឋានប្រតិបត្តិតាម
នាយក/នាយិកា
ហិរញ្ញវត្ថុ
នាយកផ្នែក
ព័ត៌មានវិទ្យា
នាយិការផ្នែករៀបចំ
ផែនការអាជីវកម្មនិង
ផ្នែកទីផ្សារ
នាយិការផ្នែកកិច្ចការ
ទូទៅ និងធនធាន
មនុស្ស
នាយក/នាយិកា
សវនកម្មផ្ទៃក្នុង
នាយក/នាយិកា
ប្រតិបត្តិតាម
នាយិការង
ហិរញ្ញវត្ថុ
នាយករងផ្នែក
ព័ត៌មានវិទ្យា
នាយក/នាយិការង
ផ្នែកទីផ្សារ
នាយក/នាយិការង
ផ្នែកធនធានមនុស្ស
នាយក/នាយិការង
ផ្នែករដ្ឋបាល
នាយក/នាយិការង
ផ្នែកបង្ហាត់បង្រៀន
នាយក/នាយិការង
សវនកម្មផ្ទៃក្នុង
នាយិការង
ប្រតិបត្តិតាម
នាយកដ្ឋានរដ្ឋបាល

៥.ភាគទុនិក

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាក់ទីភីតល ភីអិលស៊ី មានដើមទុនចុះបញ្ជីចំនួន ២០ លានដុល្លារអាមេរិក (សមមូលនឹង ៨០ពាន់លានរៀល) ដែលបានមកពីការវិនិយោគ ១០០% ពីក្រុមហ៊ុន Business Partner Co.,Ltd ប្រទេសជប៉ុន។

ក្រុមហ៊ុន Business Partner គឺក្រុមហ៊ុនដែលបានឈរជើងនៅប្រទេសជប៉ុនអស់រយៈកាលជាង ២០ឆ្នាំ ក្នុងការផ្តល់សេវាឥណទានបង់រំលស់។ Business Partner មានទ្រព្យសកម្ម ១០០,៤៣៦,៦១៤,៥៨៥ យេន គិតត្រឹមឆ្នាំ២០២២ ។

៦. ក្រុមប្រឹក្សាភិបាល

លោក Ryosuke KATAOKA ជាប្រធានក្រុមប្រឹក្សាភិបាល

លោក Ryosuke KATAOKA ជាប្រធានក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីតល ភីអិលស៊ី ។ លោកត្រូវ បានតែងតាំងនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២ ហើយមុនចូលកាន់តំណែងជាប្រធានក្រុមប្រឹក្សាភិបាល លោកធ្លាប់មានបទពិសោធន៍ជាង ១០ឆ្នាំ នៅក្នុងវិស័យហិរញ្ញវត្ថុ ។ លោកធ្លាប់មានបទពិសោធន៍ក្នុងតំណែងជាច្រើនដូចជា ប្រធានផ្នែកទីផ្សារ ប្រធាននាយកដ្ឋានផែនការសាជីវកម្ម អស់រយៈពេលជាច្រើនឆ្នាំ។ លោកក៏ធ្លាប់មានបទពិសោធន៍ជាអគ្គនាយកក្រុមហ៊ុនមួយអស់រយៈពេល ៣ ឆ្នាំផងដែរ ។ សព្វថ្ងៃនេះលោកកំពុងបម្រើការក្នុងមុខតំណែងជានាយកនាយកដ្ឋានផែនការសាជីកម្មនៅក្រុមហ៊ុន Business Partner Co.,Ltd ទីក្រុងតូក្យូ ប្រទេស ជប៉ុន ។

ប្រវត្តិសិក្សា លោកបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធុរកិច្ចពី Business Breakthrough University ប្រទេសជប៉ុន។

លោក Tatsuhiro KURIHARA ជាអភិបាល និងជាអគ្គនាយក

លោក Tatsuhiro KURIHARA ជាអភិបាល និងជាអគ្គនាយក នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីតល ភីអិសស៊ី ។ ក្នុងវិស័យហិរញ្ញវត្ថុលោកមានបទពិសោធន៍ជាង ៣០ឆ្នាំ ដោយលោកបានឆ្លងកាត់ និងមានចំណេះដឹងជាច្រើនផ្នែក ផងដែរ ដូចជា៖ ចំណេះដឹងខាងផ្នែកប្រតិបត្តិការហិរញ្ញវត្ថុ ផ្នែកច្បាប់និងប្រតិបត្តិតាម (AML) ផ្នែកទីផ្សារ និងផ្នែកផែនការសាជីកម្មជាដើម ។ បច្ចុប្បន្នលោកក៏មានតួនាទី ជាអភិបាល នៃក្រុមហ៊ុន Business Partner Co.,Ltd ទីក្រុងតូក្យូ ប្រទេសជប៉ុនផងដែរ ។

លោក Yutaka TANIMOTO ជាអភិបាល និងជាអគ្គនាយករង

លោក Yutaka TANIMOTO ជាអភិបាល និងជាអគ្គនាយករង នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីតល ភីអិសស៊ី ។ លោកមានបទពិសោធន៍ក្នុងវិស័យហិរញ្ញវត្ថុអស់រយៈពេល ១៦ ឆ្នាំ ។ ក្នុងនោះដែរលោកក៏មានចំណេះ ដឹងផ្នែកទីផ្សារ ផ្នែកព័ត៌មានវិទ្យា គណនេយ្យ ការធ្វើផែនការសាជីវកម្ម និងការត្រួតពិនិត្យឥណទានជាដើម ។

ប្រវត្តិសិក្សា លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពីសាកលវិទ្យាល័យ Business Breakthrough ប្រទេស ជប៉ុន ។

លោក Masao SUGITA ជាអភិបាល

លោក Masao SUGITA ជាអភិបាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ៉ាភីតល ភីអិលស៊ី ។ លោកមានបទពិសោធន៍ក្នុងវិស័យហិរញ្ញវត្ថុ ធានារ៉ាប់រង និងក្រុមហ៊ុនប្រឹក្សាយោបល់ អស់រយៈពេល ១៥ ឆ្នាំ។ ក្នុងបទពិសោធន៍ការងាររបស់លោក គឺលោកធ្លាប់ជាប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ ជាអគ្គនាយក និង ជាប្រធានគណៈកម្មាធិការសវនកម្មផងដែរ។ បច្ចុប្បន្នលោកក៏មានតួនាទីជាអភិបាល នៃក្រុមហ៊ុន NFC Holdings ទីក្រុងតូក្យូ ប្រទេសជប៉ុនផងដែរ ។

លោក ម៉ាឡាយ ខេមសូលី ជាអភិបាលឯករាជ្យ និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ

លោកម៉ាឡាយខេមសូលីមានតួនាទីជាអភិបាលឯករាជ្យនិងជាប្រធានគណៈកម្មាធិការហានិភ័យ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ៉ាភីតល ភីអិលស៊ី ។ ជុំវិញបទពិសោធន៍ការងារ លោកធ្លាប់មានបទពិសោធន៍ជាង៣០ឆ្នាំក្នុងវិស័យហិរញ្ញវត្ថុនិងធានារ៉ាប់រងហើយលោកបានឆ្លងកាត់មុខតំណែងជាច្រើនដូចជាជាទីប្រឹក្សាធានារ៉ាប់រងជាអគ្គនាយកហិរញ្ញវត្ថុនិងជាអគ្គនាយកត្រួតពិនិត្យហិរញ្ញវត្ថុ ។លោកក៏មានបទពិសោធន៍ជានាយកគ្រប់គ្រងរតនាគារ និងជាប្រធានគណនេយ្យផងដែរ ។ លើសពីនេះទៅទៀត លោកក៏ធ្លាប់ជាអនុប្រធានផ្នែកស្ថានភាពរូបីយវត្ថុ នៃនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនៅធនាគារជាតិ នៃកម្ពុជា ។

ប្រវត្តិសិក្សា លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ចពីសកលវិទ្យាល័យរដ្ឋដាហ្ស្សង់(Dagestan)និងថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធុរកិច្ចពីសាកលវិទ្យាល័យ Charles Stuart ប្រទេស អូស្ត្រាលី។

លោកស្រី ស៊ិន ស៊ីឡែន ជាអភិបាលឯករាជ្យ និងជាប្រធានគណៈកម្មាធិការសវនកម្ម

លោកស្រី ស៊ិន ស៊ីឡែន ជាអភិបាលឯករាជ្យ និងជាប្រធានគណៈកម្មាធិការសវនកម្ម ។ លោកស្រីមានបទ ពិសោធន៍២០ឆ្នាំ ក្នុងវិស័យគណនេយ្យនិងហិរញ្ញវត្ថុ។ លោកស្រីជាសវនករ នៅក្រុមហ៊ុន ប្រាយវ៉ែតធ័រហាវ៉ូតើស៍ (PwC) រយៈពេល៨ឆ្នាំ ដែលក្នុងនោះ រយៈពេលពីរឆ្នាំនៅប្រទេសអង់គ្លេស ។ លោកស្រីជាទីប្រឹក្សាហិរញ្ញវត្ថុជាអ្នកត្រួតពិនិត្យគុណភាពសវនកម្មនៅនិយ័តករគណនេយ្យនិងសវនកម្ម(ACAR) និងជានាយិកាហិរញ្ញវត្ថុនៅក្រុមហ៊ុន ក្នុងស្រុកជាច្រើនឆ្នាំ ។

លោកស្រី ស៊ិន ស៊ីឡែន ជាសមាជិកអេស៊ីស៊ីអេ (a fellow of ACCA) និង ជាសមាជិកនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (a member of KICPPA)។

៧. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

គណៈកម្មាធិការសវនកម្ម

សមាភាពនៃគណៈកម្មាធិការសវនកម្មអនុលោមតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាដែលបានចែងដូចតទៅ៖

- គណៈកម្មាធិការសវនកម្មត្រូវដឹកនាំដោយអភិបាលឯករាជ្យនៃក្រុមប្រឹក្សាភិបាល
- ត្រូវមានសមាសភាពយ៉ាងហោចណាស់ បុគ្គលឯករាជ្យម្នាក់ ដែលមានបទពិសោធន៍ផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ
- ត្រូវមានសមាសភាពយ៉ាងហោចណាស់ បុគ្គលឯករាជ្យម្នាក់ ដែលមានជំនាញផ្នែកច្បាប់ និងធនាគារ

គណៈកម្មាធិការសវនកម្មរបស់អាក់ទីវភីតលមានសមាជិកចំនួន ៣ រូប មកពីក្រុមប្រឹក្សាភិបាល ដែលដឹកនាំដោយសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ និងមានសមាជិកដូចខាងក្រោម៖

១- លោកស្រី ស៊ិន ស៊ីឡែន	អភិបាលឯករាជ្យ	ប្រធាន
២- លោក Ryosuke KATAOKA	ប្រធានក្រុមប្រឹក្សាភិបាល	សមាជិក
៣- លោក ម៉ាឡាយ ខេមសូលី	អភិបាលឯករាជ្យ	សមាជិក

គណៈកម្មាធិការសវនកម្មមានតួនាទីនិងភារៈកិច្ចទទួលខុសត្រូវដូចខាងក្រោម៖

- ធានាឲ្យមានការអនុវត្តតាមលក្ខខណ្ឌតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ព្រមទាំងធានាថាព័ត៌មានដែលផ្តល់ជូនសាធារណជន និងធនាគារជាតិនៃកម្ពុជា ត្រឹមត្រូវ និងជឿជាក់បាន
- វាយតម្លៃភាពសមស្របនៃវិធីសាស្ត្រគណនេយ្យ ដែលគេប្រើដើម្បីរៀបចំគណនីដោយឡែក និងគណនីរួមបញ្ចូលគ្នា
- វាយតម្លៃគុណភាពនៃការត្រួតពិនិត្យផ្ទៃក្នុង តួនាទីនិងការទទួលខុសត្រូវលម្អិតរបស់គណៈកម្មាធិការសវនកម្ម។

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ មានសមាសភាពចំនួន៣រូប មកពីក្រុមប្រឹក្សាភិបាល ដែលដឹកនាំដោយសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ និងមានសមាជិកដូចខាងក្រោម៖

១- លោក ម៉ាឡាយ ខេមសូលី	ប្រធាន
២-លោក Ryosuke KATAOKA	សមាជិក
៣-លោកស្រី ស៊ិន ស៊ីឡែន	សមាជិក

គណៈកម្មាធិការគ្រប់គ្រងហានិភ័យត្រូវទទួលខុសត្រូវលើ៖

- សំវិធានធនឥណទាន
- គ្រប់គ្រងហានិភ័យឥណទាន
- គ្រប់គ្រងហានិភ័យដើមទុន
- គ្រប់គ្រងហានិភ័យសន្ទនីយភាព និងប្រភពដើមទុន
- គ្រប់គ្រងហានិភ័យប្រតិបត្តិការ
- គ្រប់គ្រងហានិភ័យប្រតិបត្តិតាម
- តាមដាន និងត្រួតពិនិត្យលើហានិភ័យផ្នែកច្បាប់ និងបរិយាកាសនយោបាយ និងគោលនយោបាយនានា
- តាមដានកម្រិតពិដាន និងអនុបាតហានិភ័យសំខាន់ៗដែលកំណត់ដោយស្ថាប័ន
- ពិនិត្យតាមដានបរិយាកាសសេដ្ឋកិច្ច និងការប្រកួតប្រជ្រែង

គណៈកម្មាធិការតែងតាំង និងអត្ថប្រយោជន៍

គណៈកម្មាធិការតែងតាំង និងអត្ថប្រយោជន៍ មានសមាសភាពចំនួន ៣រូប មកពីក្រុមប្រឹក្សាភិបាល និងមានសមាជិកដូចខាងក្រោម៖

១- លោក ម៉ាឡាយ ខេមសូលី	ប្រធាន
២-លោក Tatsuhiro KURIHARA	សមាជិក
៣-លោកស្រី ស៊ិន ស៊ីវ៉ែន	សមាជិក

គណៈកម្មាធិការតែងតាំង និងអត្ថប្រយោជន៍ ត្រូវទទួលខុសត្រូវលើ៖

- ធ្វើឲ្យកាន់តែប្រសើរឡើងនូវការអនុវត្តគោលនយោបាយ បទបញ្ជាផ្ទៃក្នុង និង នីតិវិធីក្នុងការគ្រប់គ្រងធនធានមនុស្ស និងការជ្រើសរើសបុគ្គលិក
- អនុវត្តប្រព័ន្ធបច្ចេកទេសព័ត៌មានថ្មីៗសម្រាបសម្រួលដល់ការគ្រប់គ្រងធនធានមនុស្ស
- អនុវត្តកម្មវិធីបណ្តុះបណ្តាលឲ្យបានទូលំទូលាយ និងឲ្យទាន់បច្ចុប្បន្នភាព
- ដំឡើងប្រាក់ខែ និងផ្តល់ប្រាក់រង្វាន់ប្រចាំឆ្នាំ ដល់បុគ្គលិក
- ពិនិត្យមើលការអនុវត្តតាមរបស់មន្ត្រី ការគ្រប់គ្រងធនធានមនុស្សស្របទៅនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា និងច្បាប់ស្តីពីការងារ។

៨. គណៈគ្រប់គ្រង

លោក TATSUHIRO KURIHARA (អគ្គនាយក)

លោក TATSUHIRO KURIHARA ជាអគ្គនាយក នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាក់ទីភីភល ភីអិសស៊ី។ ក្នុងវិស័យហិរញ្ញវត្ថុលោកមានបទពិសោធន៍ជាង ៣០ឆ្នាំ ដោយលោកបានឆ្លងកាត់ និងមានចំណេះដឹងជាច្រើនផ្នែកផងដែរ ដូចជា៖ ចំណេះដឹងខាងផ្នែកប្រតិបត្តិការហិរញ្ញវត្ថុ ផ្នែកច្បាប់និងប្រតិបត្តិតាម (AML) ផ្នែកទីផ្សារ និងផ្នែកផែនការសាជីកម្មជា ដើម។ បច្ចុប្បន្នលោកក៏មានតួនាទី ជាអភិបាល នៃក្រុមហ៊ុន Business Partner Co.,Ltd ទីក្រុងតូក្យូ ប្រទេសជប៉ុន ផងដែរ ។

លោក Yutaka Tanimoto (អគ្គនាយករង)

លោក Yutaka TANIMOTO ជាអគ្គនាយករង នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ ភីភល ភីអិសស៊ី ។ លោកមានបទពិសោធន៍ក្នុងវិស័យហិរញ្ញវត្ថុអស់រយៈពេល ១៦ ឆ្នាំ។ ក្នុងនោះដែរ លោកក៏មានចំណេះដឹងផ្នែកទីផ្សារ ផ្នែកព័ត៌មានវិទ្យា គណនេយ្យ ការធ្វើផែនការសាជីវកម្ម និងការត្រួតពិនិត្យឥណទានជាដើម។
ប្រវត្តិសិក្សា លោកបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ ពីសាកលវិទ្យាល័យ Business Breakthrough ប្រទេស ជប៉ុន។

លោក សុន គឹមសា (នាយកចាត់ការទូទៅ)

លោកសុនគឹមសា ជាជនជាតិខ្មែរ ចូលបម្រើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី ចាប់តាំង ពីឆ្នាំ ២០១៤ ដោយចាប់ផ្តើមពីបុគ្គលិកទូទៅ ។ ក្រោយមកលោកត្រូវបានដំឡើងតួនាទីជាជំនួយការប្រធានគ្រប់គ្រងហើយបន្ទាប់មកត្រូវបានតែងតាំងជា ប្រធានសាខា ។
លោកត្រូវបានតែងតាំងជា នាយកចាត់ការទូទៅនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី នៅក្នុងឆ្នាំ ២០១៨ ។
ជាមួយនឹងអាជីពជាង ៩ ឆ្នាំនៅក្នុងវិស័យហិរញ្ញវត្ថុ លោក និងក្រុមគ្រួសាររបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី បាននឹងកំពុងខិតខំប្រឹងប្រែងដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍន៍ និងប្រជាជននៅក្នុងប្រទេសកម្ពុជាផងដែរ។

លោកស្រី ជា ធិតា (នាយិកានាយកដ្ឋានប្រតិបត្តិតាម)

លោកស្រី ជា ធិតា ជាជនជាតិខ្មែរ ចូលបម្រើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភលភីអិលស៊ី នៅឆ្នាំ២០១៥ ក្នុងតួនាទីជាប្រធានគណនេយ្យ ។ គិតត្រឹមខែមេសា ឆ្នាំ២០២១ លោកស្រី ជា ធិតា បានបំពេញតួនាទីជា នាយិកានាយកដ្ឋានប្រតិបត្តិតាម ។ មុនពេលចូលបម្រើការងារជាមួយ អាក់ទីវភីភល ភីអិលស៊ី លោកស្រី ជា ធិតា ធ្លាប់មានបទពិសោធន៍ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុនិងក្រុមហ៊ុនដទៃទៀតរយៈពេលសរុបជាង១០ឆ្នាំដែលមានតួនាទីជានាយិកាផ្នែកគណនេយ្យហិរញ្ញវត្ថុ និងនាយិកានាយកដ្ឋានរដ្ឋបាល ។
លោកស្រី ជា ធិតា បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ និងហិរញ្ញវត្ថុនៅសាកលវិទ្យាបៀលប្រាយ ឆ្នាំ២០០៩ ។ បច្ចុប្បន្នលោកស្រី បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញហិរញ្ញវត្ថុ និងធនាគារ ។ លោកស្រីក៏បានឆ្លងកាត់វគ្គសិក្សាជំនាញផ្សេងៗដូចជាគណនេយ្យកុំព្យូទ័រ Quick Books, Access, Excel ជាដើម។

លោក ១ឧ្យ ប៊ុនឈឿន (នាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង)

លោក**ឧ១ឧ្យ ប៊ុនឈឿន**ជាជនជាតិខ្មែរបានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ:ភីភល ភីអិលស៊ី ជាប្រធានសវនកម្មផ្ទៃក្នុង ក្នុងខែតុលា ឆ្នាំ២០១៩ ។ លោកបានបញ្ចប់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ជំនាញហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យមេគង្គកម្ពុជានិងទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងធុរកិច្ចជំនាញហិរញ្ញវត្ថុនិងធនាគារនៅសាកលវិទ្យាល័យវ:ស្ទ្រីន ។ លោកមានបទពិសោធន៍ជាង ១០ឆ្នាំ ក្នុងសកម្មភាពមីក្រូហិរញ្ញវត្ថុនៅក្នុងគ្រឹះស្ថានដែលទទួលស្គាល់មួយក្នុងប្រទេសកម្ពុជាក្នុងមុខតំណែងផ្សេងៗ ដូចជា សវនករផ្ទៃក្នុង បន្ទាប់មកត្រូវបានតែងតាំងជាប្រធានសវនកម្មផ្ទៃក្នុងនៅខែកញ្ញា ឆ្នាំ ២០១៧។ លោកបានចូលរួមវគ្គសិក្សាជាច្រើនដូចជា: ជំនាញវាយតម្លៃហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុងសវនកម្មសម្រាប់ការលួចបន្លំផ្ទៃក្នុងការរៀបចំផែនការណ៍ និងគ្រប់គ្រងពេលវេលា ការគ្រប់គ្រងហានិភ័យស្ថាប័នមីក្រូហិរញ្ញវត្ថុនិងមូលដ្ឋានពន្ធជាដើម។

កញ្ញា សេង ចាន់ជា (នាយិកានាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ)

កញ្ញា សេង ចាន់ជា ជាជនជាតិខ្មែរ ចូលបម្រើការងារជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ អាក់ទីវ:ភីភល ភីអិលស៊ី ចាប់ពីខែមិនាឆ្នាំ ២០១៥ ដែលមានតួនាទីជាអ្នកបកប្រែ និងលេខារបស់អគ្គនាយក ហើយបច្ចុប្បន្នកញ្ញាមានតួនាទីជានាយិកានាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ។ មុនពេលកញ្ញាចូលបំរើការងារជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ អាក់ទីវ:ភីភល ភីអិល ស៊ី កញ្ញាធ្លាប់មានបទពិសោធន៍ធ្វើការនៅក្រុមហ៊ុន Business Partner Co.,Ltd នៃប្រទេសជប៉ុន រយៈពេលមួយឆ្នាំ ។

កញ្ញាបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញអប់រំឯកទេសភាសាអង់គ្លេសនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញឆ្នាំ២០០៥ និងបានបញ្ចប់ថ្នាក់ អនុបណ្ឌិតផ្នែកអប់រំនៅសាកលវិទ្យាល័យនិហុងនៃប្រទេសជប៉ុនឆ្នាំ២០១១។ បច្ចុប្បន្នកញ្ញាកំពុងសិក្សានៅ Cam Ed Business School ដើម្បីទទួលបានសញ្ញាបត្រអន្តរជាតិ ACCA ។

លោក ១ស្រី លឹម លីដា (នាយិកាផ្នែកកិច្ចការទូទៅ និងធនធានមនុស្ស)

លោក១ស្រី លឹម លីដា ជាជនជាតិខ្មែរ ចូលបម្រើការងារជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ:ភីភល ភីអិលស៊ី ចាប់ពីខែកញ្ញា ឆ្នាំ ២០១៣ ក្នុងមុខតំណែងផ្សេងៗជាច្រើនដូចជាមន្ត្រីផ្នែកលក់ ប្រធានក្រុមគ្រូបង្គោល មន្ត្រីជាន់ខ្ពស់ផ្នែកទំនាក់ទំនងអតិថិជន និងនាយិកាគ្រូបង្គោល។ ចាប់ពីខែមីករា ឆ្នាំ២០១៩ មកដល់បច្ចុប្បន្នមានតួនាទីជានាយិកាកិច្ចការទូទៅ និងធនធានមនុស្ស។ មុនពេល លោកស្រី លឹម លីដា ចូលបម្រើការងារជាមួយ អាក់ទីវ: ភីភល ភី អិលស៊ី លោកស្រីធ្លាប់មានបទពិសោធន៍ប្រាំឆ្នាំ ក្នុងតួនាទីជាមន្ត្រីទំនាក់ទំនងអតិថិជនតាមទូរស័ព្ទ ។ លោកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញធនាគារ និងហរិញ្ញវត្ថុ ក្នុងឆ្នាំ២០១២ នៅសកលវិទ្យាល័យន័រតុន។ បច្ចុប្បន្នលោកស្រីកំពុងបន្តការសិក្សាថ្នាក់ អនុបណ្ឌិតជំនាញគ្រប់គ្រងពាណិជ្ជកម្ម នៅសាកលវិទ្យាល័យបៀលប្រាយ ។ លោកស្រីក៏បាន ឆ្លងកាត់វគ្គសិក្សាជំនាញផ្សេងៗដូចជា ច្បាប់ស្តីពីការងារ, ការគ្រប់គ្រងធនធាន មនុស្សប្រកបដោយ ប្រសិទ្ធភាពក្នុងវិជ្ជាជីវៈធនធានមនុស្ស, ភាពជាអ្នកដឹកនាំ, វគ្គបណ្តុះ បណ្តាលគ្រូហ្វឹកហ្វឺន, ការរៀបចំសូចនាករ និងការគ្រប់គ្រងសមិទ្ធកម្ម ការងាររបស់បុគ្គលិក, វិធីសាស្ត្រគណនា ក្រោមច្បាប់ការងារកម្ពុជា, ការគ្រប់គ្រងធនធានមនុស្ស និងការអនុលោមតាមច្បាប់សម្រាប់ស្ថាប័នហិរញ្ញវត្ថុ ។

លោក ឯក ស៊ីនដេង (នាយកផ្នែកព័ត៌មានវិទ្យា)

លោក **ឯក ស៊ីនដេង** ជាជនជាតិខ្មែរ ចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវ៉ាភីតល ភីអិលស៊ី ចាប់ពីខែមិថុនា ឆ្នាំ២០១៥ ក្នុងតួនាទីជាប្រធានផ្នែកព័ត៌មានវិទ្យា ។ មុនពេលលោក ឯក ស៊ីនដេង ចូលបំពេញការងារជាមួយ អាក់ទីវ៉ាភីតល ភីអិលស៊ី លោកធ្លាប់មានបទពិសោធន៍ជាងប្រាំឆ្នាំ ក្នុងតួនាទីជាមន្ត្រីជាន់ខ្ពស់ផ្នែកព័ត៌មានវិទ្យា និងមានបទពិសោធន៍ជាច្រើនទាក់ទងនឹងការបង្កើតគេហទំព័រនិងបង្កើតប្រព័ន្ធប្រើប្រាស់ផ្សេងៗទៀត។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញវិទ្យាសាស្ត្រ កុំព្យូទ័រ និងវិស្វករ ក្នុងឆ្នាំ២០០៩ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ក្នុងឆ្នាំ២០១២ នៅសកលវិទ្យាល័យជាតិគ្រប់គ្រង ។

៩. សកម្មភាពផ្សេងៗរបស់គ្រឹះស្ថាន

ក. អត្តពលកម្មប៉ារ៉ាឡាំពិក

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី បានចូលរួមសហការណ៍ឧបត្ថម្ភលើការប្រកួតកីឡាអត្តពលកម្មប៉ារ៉ាឡាំពិក លើកទី០៤ ក្នុងឆ្នាំ២០២២ ដែលត្រូវបានប្រារព្ធពិធីបើកក្រោមអធិបតីភាព **ឯកឧត្តម ម៉ាត់ ចំរើន** រដ្ឋលេខាធិការក្រសួងទេសចរណ៍ និងជាអគ្គលេខាធិការ។

គ្រឹះស្ថានមីក្រូហរិញ្ញវត្ថុ អាក់ទីវភីភល តែងតែចូលរួមសហការណ៍គាំទ្រនិងឧបត្ថម្ភជានិច្ច សម្រាប់ព្រឹត្តិការណ៍នៃការប្រកួតកីឡាអត្តពលកម្មប៉ារ៉ាឡាំពិកនេះ មិនថាឆ្នាំនេះឬឆ្នាំមុនៗ ។

អេភី សូមធ្វើការគាំទ្រដល់បងប្អូនជនពិការក៏ដូចជាប្រជាជនកម្ពុជាទាំងអស់ចូលរួមលេងកីឡាទាំងអស់គ្នា។ "ប្រជាជនម្នាក់លេងកីឡាមួយមុខ កីឡារស់ក្នុងសន្តិភាព កម្ពុជាស្អាត គ្មានគ្រឿងញៀន និងគ្មានគ្រោះថ្នាក់ចរាចរណ៍"។

ខ. កាកបាទក្រហមកម្ពុជា

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីតល ភីអិលស៊ី មានកិត្តិយសចូលរួមឧបត្ថម្ភថវិកាចំនួន ២០,០០០,០០០ រៀល ក្នុងឱកាសខួបទី ១៥៩ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០២២ ក្រោមប្រធានបទ «ទាំងអស់គ្នារួមជាមួយកាកបាទក្រហមកម្ពុជា ដោះស្រាយបញ្ហាប្រឈមនានា និងបន្ត ពង្រឹងភាពធន់សហគមន៍ ។

ប័ណ្ណថ្លែងអំណរគុណ
ប្រធានកាកបាទក្រហមកម្ពុជា
សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីតល ភីអិលស៊ី

ដែលបានឧបត្ថម្ភថវិកាចំនួន 20,000,000 រៀល

អបអរសាទរខួបទី ១៥៩ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ២០២២ ក្រោមប្រធានបទ
"ទាំងអស់គ្នារួមជាមួយកាកបាទក្រហមកម្ពុជា ដោះស្រាយបញ្ហាប្រឈមនានា និងបន្តពង្រឹងភាពធន់សហគមន៍"។
កាកបាទក្រហមកម្ពុជា នឹងយកចិត្តទុកដាក់ប្រើប្រាស់អំណោយដ៏សប្បុរសនេះ: ដើម្បីបម្រើសកម្មភាពមនុស្សធម៌
ជួយដល់ប្រជាពលរដ្ឋ ដែលជួបការលំបាកដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ។

សូមប្រសិទ្ធពរ ឯកសូស្តីមហាប្រសើរ និងព្រះពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ចុះបញ្ជីលេខ: ០៨០៨/២២ ក.ក.ទ

ថ្ងៃអង្គារ ១រោចខែ ចេត្រ ឆ្នាំឆ្លូ ត្រីស័ក ព.ស.២៥៦៥
ភ្នំពេញ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០២២

សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន

នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ គ្រឹះស្ថាន ក៏បានចូលរួមបរិច្ចាកទឹកប្រាក់បន្ថែមចំនួន ៣,០០០ដុល្លារ អាមេរិក ក្នុងគោលបំណងឧបត្ថម្ភគាំទ្រការងារមនុស្សធម៌ ដើម្បីជួយសម្រាលការលំបាកចំពោះ ប្រជាពលរដ្ឋដែលបានទទួលរងផលប៉ះពាល់ដោយសារគ្រោះទឹកជំនន់។

លិខិតលិខិតសរសើរ

លិខិតលិខិតសរសើរ
ប័ណ្ណថ្លែងអំណរគុណ
ប្រធានកាកបាទក្រហមកម្ពុជា
សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវកីឡា ភីអិលស៊ី

ដែលបានឧបត្ថម្ភថវិកាចំនួន 3,000 ដុល្លារអាមេរិក

កាកបាទក្រហមកម្ពុជា នឹងយកចិត្តទុកដាក់ប្រើប្រាស់អំណោយដ៏សប្បុរសនេះ ដើម្បីបម្រើសកម្មភាពមនុស្សធម៌
ជួយដល់ប្រជាពលរដ្ឋ ដែលជួបការលំបាក ដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ។

សូមប្រសិទ្ធពរ បវរសួស្តីមហាប្រសើរ និងព្រះពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ចុះបញ្ជីលេខ: ២៣៩៦/២២ ក្រាក.ទទ

ថ្ងៃព្រហស្បតិ៍ ៣កើត ខែកត្តិក ឆ្នាំឆ្លូវ ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២

CAMBODIAN RED CROSS

សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន

គ. កម្មពិធីលៀងសាយភោជន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីតល ភីអិលស៊ី បានរៀបចំ កម្មពិធីលៀងសាយភោជន ដើម្បីជួបជុំ និងថ្លែងអំណរគុណ ដល់ដៃគូរសហការ សម្រាប់ ការជួយជ្រោមជ្រែង និងការសហការអាជីវកម្មដ៏ល្អ សម្រាប់រយៈពេលច្រើនឆ្នាំកន្លងមក។ ជាមួយគ្នានេះដែរ យើងក៏បានរៀបចំកម្មវិធីប្រគល់ពានរង្វាន់ជូនដល់ដៃគូរសហការឆ្នើមរបស់គ្រឹះស្ថានក្នុងអំឡុងឆ្នាំ ២០២០ និង ២០២១ ។

ឃ. បរិច្ចាគឈាម សង្គ្រោះជីវិត ពិតជួយសង្គមជាតិ

នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ បុគ្គលិករបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ អាក់ទីវភីកល ភីអិលស៊ី ការិយាល័យកណ្តាល និងសាខានានាក្នុងរាជធានីភ្នំពេញ បានរួមគ្នាបរិច្ចាគឈាម ក្រោមប្រធានបទ "បរិច្ចាគឈាម សង្គ្រោះជីវិត ពិតជួយសង្គមជាតិ"។

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីកល ផ្តល់ឈាម គឺផ្តល់ក្តីស្រលាញ់ ផ្តល់ឈាម គឺសង្គ្រោះជីវិត!!

១. ម៉ារ៉ាតុងលើកទី១០

ទិវារត់ប្រណាំងភ្នំពេញអន្តរជាតិពាក់កណ្តាលម៉ារ៉ាតុងលើកទី១០ ប្រចាំខែមិថុនា ឆ្នាំ២០២២។
"កីឡានាំមកនូវសុខភាពល្អ!"

ច. កម្មវិធីចាប់រង្វាន់ និងប្រគល់រង្វាន់ជូនដល់អតិថិជន

បានរៀបចំកម្មវិធីចាប់ឆ្នោត និងប្រគល់រង្វាន់ជូនទៅអតិថិជនទាំងអស់ដែលបានប្រើប្រាស់គ្រប់សេវាកម្ម របស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីកល ភីអិលស៊ី ។ នៅគ្រប់សាខាទាំងអស់របស់ គ្រឹះស្ថាន ចាប់ពីថ្ងៃទី ០២ ខែមករា ឆ្នាំ ២០២២ រហូតដល់ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០២២ ។

ឆ. ចាប់រង្វាន់កាតសាំងផ្តល់ជូនដល់អតិថិជន

ការចាប់រង្វាន់កាតសាំងជូនដល់អតិថិជន ដែលទទួលបានកម្ចីបង់រំលស់ម៉ូតូ និងរថយន្តពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ខែកក្កដា ឆ្នាំ ២០២២។

៩. ពិធីបើកដំណើរការកិច្ចសហការ សាលាបឋមសិក្សាព្រះនរោត្តម និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវតីតល តីអិលស៊ី

ដើម្បីលើកម្ពស់ និងពង្រឹងវិស័យអប់រំបែបស្ទ្រីម(STEM) នៅកម្រិតអប់រំថ្នាក់បឋម គ្រឹះស្ថានបានអញ្ជើញចូលរួម ឧបត្ថម្ភថ្នាក់រៀនកូដឌីង និង WiFi ទៅកាន់សាលាបឋមសិក្សាព្រះនរោត្តម ។

ឈ. គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល បានចូលរួមបរិច្ចាគទឹកប្រាក់ចំនួន ៣,០០០ ដុល្លារអាមេរិក តាមរយៈសមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជា ទៅកាន់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងគោលដៅសម្រាប់ជួយឧបត្ថម្ភដល់ប្រជាពលរដ្ឋដែលរងគ្រោះ ដោយគ្រោះមហន្តរាយគ្រោះទឹកជំនន់ទឹកភ្លៀង ។

១០. ទីស្នាក់ការរបស់ក្រុមហ៊ុនស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវតីល ភីអិលស៊ី

០១. ទីស្នាក់ការកណ្តាល

អាសយដ្ឋាន: អាគារលេខ៨៨ ផ្លូវលេខ២១៤ កែងនឹងផ្លូវលេខ១១៣ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ

ទូរស័ព្ទ: +៨៥៥ ២៣ ២១៤ ២៥៥

+៨៥៥ ៧៨ ៧៧៧ ៣៤០

០២. សាខា បឹងកេងកង៣

អាសយដ្ឋាន: អាគារលេខ១៤៩C ផ្លូវលេខ១៤៣ សង្កាត់បឹងកេងកង៣ ខណ្ឌប៉ាងកេងកង រាជធានីភ្នំពេញ

ទូរស័ព្ទ: +៨៥៥ ២៣ ២២៤ ១៥៦

+៨៥៥ ៧៨ ៧៧៧ ២៥៩

០៣. សាខា សៀមរាប

អាសយដ្ឋាន: អាគារលេខ៨៨ ផ្លូវស៊ីវ៉ុត្តា ភូមិមណ្ឌល សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប

ទូរស័ព្ទ: +៨៥៥ ៧៨ ២៥៤ ១១២

+៨៥៥ ១០ ៨២២ ០៣០

០៤. សាខា ខណ្ឌសែនសុខ

អាសយដ្ឋាន: អាគារលេខ៨៧-៨៩ ផ្លូវលេខ១០១៩ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ: +៨៥៥ ១០ ៩៦០ ៦១៩

+៨៥៥ ៧៨ ៧៧៧ ២៥១

០៥. សាខា ខេត្តបាត់ដំបង

អាសយដ្ឋាន: អាគារលេខ២៣-២៥ ផ្លូវលេខ៣ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

ទូរស័ព្ទ: +៨៥៥ ៥៣ ៧៣២ ៦០០

+៨៥៥ ៧១ ៣៣១ ៦៧៧៧

០៦. សាខា ខេត្តកំពង់ចាម

អាសយដ្ឋាន: អាគារលេខ៦៤ មហាវិថីព្រះមុន្នីវង្ស សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម

ទូរស័ព្ទ: +៨៥៥ ៤២ ២១០ ៨៨៧

+៨៥៥ ៧១ ៣២៣ ៩៧៧៧

០៧. សាខា ខណ្ឌទួលគោក

អាសយដ្ឋាន: អាគារលេខ៣A ផ្លូវលេខ៣៥៥ ភូមិ១ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំ

ទូរស័ព្ទ: +៨៥៥ ២៣ ២៣១ ៩១២

+៨៥៥ ៨១ ៩៩៤ ៩៥៨

+៨៥៥ ៦១ ៤២១ ១១២

០៨. សាខា ខេត្តកណ្តាល

អាសយដ្ឋាន: អាគារលេខ១៣៧D ផ្លូវជាតិលេខ២ ភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល

ទូរស័ព្ទ: +៨៥៥ ២៣ ៤២៥ ៦៧៧

+៨៥៥ ២៣ ៤២៥ ៦៧៨

+៨៥៥ ១៧ ២៧៦ ០៣១

០៩. សាខា ខេត្តតាកែវ

អាសយដ្ឋាន: អាគារលេខ២ សង្កាត់រការក្នុង ក្រុងដូនកែវ ខេត្តតាកែវ

ទូរស័ព្ទ: +៨៥៥ ៦១ ២០៤ ៤៤៥

+៨៥៥ ៨១ ៩៩៤ ៨៧១

១០. សាខា ខណ្ឌច្បារអំពៅ

អាសយដ្ឋាន: ផ្ទះលេខ១៥សDE0-E1 ផ្លូវជាតិលេខ១ សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

ទូរស័ព្ទ: +៨៥៥ ២៣ ២៣១ ៤១៣

+៨៥៥ ៨៦ ២៤៥ ៥១២

+៨៥៥ ៩២ ៧៦៥ ៥៧០

១១. សាខា ខណ្ឌមានជ័យ

អាសយដ្ឋាន: អាគារលេខ២៧ ផ្លូវសម្តេចព្រះមុនីរ៉ែត (២១៧) ភូមិដំណាក់ធំទី១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ: +៨៥៥ ២៣ ២៣១ ៤១២

+៨៥៥ ៩៨ ៨០៤ ៧៣៩

+៨៥៥ ១២ ៤២៥ ៩៣៤

១២. សាខា ខេត្តកំពង់ស្ពឺ

អាសយដ្ឋាន: អាគារលេខ២៩៦ ផ្លូវជាតិលេខ៤ ភូមិពាណិជ្ជកម្ម សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

ទូរស័ព្ទ: +៨៥៥ ២៥ ២១០ ២៣៦

+៨៥៥ ១៧ ៥២២ ០២៦

+៨៥៥ ៧០ ៥២៣ ៧៨៣

១៣.សាខា ខេត្តបន្ទាយមានជ័យ

អាសយដ្ឋាន: អាគារលេខ៤១៥ ភូមិ៣ ផ្លូវជាតិលេខ៥ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ

ទូរស័ព្ទ: +៨៥៥ ៥៤ ៧១០ ៥១៣
+៨៥៥ ១២ ៤២៥ ៩៦៤
+៨៥៥ ៨៦ ២៤៥ ០១៣

១៤. សាខា ខណ្ឌជ្រោយចង្វារ

អាសយដ្ឋាន: អាគារលេខ១0B (F១0) ផ្លូវជាតិលេខ ៦ ភូមិ៣ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

ទូរស័ព្ទ: +៨៥៥ ១២ ៤៣0 ៧៩១
+៨៥៥ ៨៦ ២៥៦ 0៤១
+៨៥៥ ៩៧ ៥៧៥ ៤៧៧៧

១៥. សាខា ខណ្ឌព្រែកព្នៅ

អាសយដ្ឋាន: ផ្លូវជាតិលេខ៥ ភូមិកណ្ដាល សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

ទូរស័ព្ទ: +៨៥៥ ២៣ ២៣0 ២៨0
+៨៥៥ ៩៥ ៣២៩ 0៣៦
+៨៥៥ ៦៩ ២២២ ៤៣៩

១៦. សាខា ខេត្តត្បូងឃ្មុំ

អាសយដ្ឋាន: ភូមិជើងឡង សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ

ទូរស័ព្ទ: +៨៥៥ ៤៥ ២១១ ១៣១
+៨៥៥ ៦៩ ៣៨៥ ២២២
+៨៥៥ ៦១ ៤0៧ ៣0៤

១៧. សាខា ខេត្តកំពង់ធំ

អាសយដ្ឋាន: អាគារលេខ៥៤៧ ផ្លូវជាតិលេខ៦ ភូមិកំពង់ធំ សង្កាត់កំពង់រទេះ ខេត្តកំពង់ធំ

ទូរស័ព្ទ: +៨៥៥ ៦២ ២១0 ២១២
+៨៥៥ ៩៥ ៤៤៣ ៨៨២
+៨៥៥ ៧0 ២២២ ៥៨៦

១៨. សាខា ខេត្តកំពង់ឆ្នាំង

អាសយដ្ឋាន: ភូមិធម្មយុត្តិ សង្កាត់ល្អេរ ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

ទូរស័ព្ទ: +៨៥៥ ៦១ ៣២៩ ៨៤៨
+៨៥៥ ៦៩ ៣៩0 ២២២
+៨៥៥ ៣១ ២១៣ ២៧៧៧

១៩. សាខា ខេត្តរតនៈគិរី

អាសយដ្ឋាន: ផ្ទះលេខ ៧៨ ភូមិជ័យជំនៈ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនៈគិរី

ទូរស័ព្ទ: +៨៥៥ ៦៩ ៦៤១ ២២២

+៨៥៥ ៧១ ២៧១ ៦៧៧៧

២០. សាខា ខេត្តក្រចេះ

អាសយដ្ឋាន: ភូមិផ្សារវែង សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ

ទូរស័ព្ទ: +៨៥៥ ៦៩ ៦៣៨ ២២២

+៨៥៥ ៨៨ ២០៦ ៩៧៧៧

២១ សាខា ស្រុកបារាយណ៍

អាសយដ្ឋាន: ផ្ទះលេខ១២ ក្រុងទី១ ភូមិព្រៃតាត្រាវ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ

ទូរស័ព្ទ: +៨៥៥ ១៥ ៥១ ៥៥ ៤៥

+៨៥៥ ៩៨ ៩៣ ៨០ ៨៨

+៨៥៥ ៩៦ ៨៨ ៧៦ ៨៩៨

២២ សាខា ខេត្តព្រះវិហារ

អាសយដ្ឋាន: ភូមិអណ្តូងពោធិ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ

ទូរស័ព្ទ: +៨៥៥ ៨១ ៣៤ ២០ ០៩

+៨៥៥ ៨៨ ៣៣ ២៥ ០២៧

+៨៥៥ ៩៧ ៥១ ៨៣ ២៦២

២៣ សាខា ខេត្តឧត្តរមានជ័យ

អាសយដ្ឋាន: ភូមិសំរោង សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ

ទូរស័ព្ទ: +៨៥៥ ១២ ៤១ ២៦ ៣៩

+៨៥៥ ៧០ ៤៣ ១២ ២២

+៨៥៥ ៦៩ ៦៤ ០២ ២២

២៤ សាខា ខណ្ឌដង្កោ

អាសយដ្ឋាន: ភូមិបុរីកម្មករ សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ: +៨៥៥ ៨៧ ៩០ ០០ ៥៨

+៨៥៥ ១៦ ៨៤ ៦១ ៩៤

+៨៥៥ ៨៦ ៨៦ ០២ ៨២

២៥ សាខា ខណ្ឌពោធិ៍សែនជ័យ

អាសយដ្ឋាន: ភូមិជម្ពូវ័ន១ សង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ: +៨៥៥ ៨៦ ៦៤ ៦៩ ៧៩

+៨៥៥ ៩៦ ៩២ ១៩ ២៨៨

+៨៥៥ ១០ ២២ ៦៥ ៧២

២៦ សាខា ខេត្តកំពត

អាសយដ្ឋាន: ផ្ទះលេខ១២៦ ផ្លូវលេខ៣ ភូមិស្វាយធំ សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត

ទូរស័ព្ទ: +៨៥៥ ៩៨ ៥៣ ២៥ ១៨

+៨៥៥ ៩៧ ២០ ៥០ ៦៣២

+៨៥៥ ៩៦ ៤១ ៥៦ ៣២២

២៧ សាខា ក្រុងប៉ោយប៉ែត

អាសយដ្ឋាន: ភូមិក្បាលកោះ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

ទូរស័ព្ទ: +៨៥៥ ១០ ៣៧ ១៣ ៤៥

+៨៥៥ ៩៧ ៩៨ ៥៣ ៥៨៦

+៨៥៥ ៨៥ ៦២ ៦៣ ០៣

២៨ .សាខា ខេត្តស្វាយរៀង

អាសយដ្ឋាន: ភូមិកៀនសាំង សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង

ទូរស័ព្ទ: +៨៥៥ ៨៨ ៥១ ១៩ ១៣៧

+៨៥៥ ៦៦ ៣២ ៥៥ ៧៥

+៨៥៥ ៩៧ ៥៦ ៣៦ ៦៦៥

២៩ .សាខា ស្រុកពាមរក៍

អាសយដ្ឋាន: ភូមិភូមិ១ ឃុំព្រៃកឧ្សាយ ខ ស្រុកពាមរក៍ ខេត្តព្រៃវែង

ទូរស័ព្ទ: +៨៥៥ ៩៣ ៧៣ ៨៩ ០៤

+៨៥៥ ៩៣ ៨៣ ៩៤ ០៧

+៨៥៥ ៩៦ ៥០ ៩១ ៩០០

https://t.me/apmfiplc

www.apmfi.com.kh

/ActivePeopleMFI

081 828 666 / 071 828 6666